**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ៦០) |
| **ដាក់ទៅ** | : | អង្គបុរេជំនុំជម្រះ |
| **ថ្ងៃដាក់** | : | ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| **ភាសាដើម** | : | អង់គ្លេស |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 20-Mar-2020, 10:15
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ អបជ: **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បន្ថែមអនុស្សរណៈរបស់ អ.ប.ជ ចុះថ្ងៃទី១២ និង ទី១៦ ខែមីនា នៅក្នុងសំណុំរឿង០០៤/២**

---

**អ្នកដាក់ឯកសារ:**
លោកស្រី Brenda J. HOLLIS
**សហព្រះរាជអាជ្ញាអន្តរជាតិ**

**ចម្លងជូន:**
លោកស្រី ជា លាង
**សហព្រះរាជអាជ្ញាជាតិ**

**អ្នកទទួលឯកសារ:**
**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

**សហមេធាវី សោ អាន**
លោក មុំ លុជ្ស
លោក Richard ROGERS
លោក Göran SLUITER

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង០០៤/២**

## I. សេចក្ដីផ្ដើម

1. សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") ស្នើសុំឲ្យអង្គបុរេជំនុំជម្រះ ("អ.ប.ជ") ដាក់បន្ថែមអនុស្សរណៈដែលបានចេញដោយចៅក្រម អ.ប.ជ កាលពីថ្ងៃទី១២ និង ទី១៦ ខែមីនា ឆ្នាំ២០២០ ក៏ដូចជាឯកសារភ្ជាប់ដែលពាក់ព័ន្ធនានាផងដែរ។ ស.ព.អ សុំស្នើបន្ថែមថា បើសិនជាឯកសារទាំងនោះមិនទាន់ត្រូវបានចាត់ថ្នាក់ជាសាធារណៈទេ សូមឲ្យ អ.ប.ជ ធ្វើឲ្យវាទៅជាសាធារណៈ។ ស.ព.អ ធ្វើសំណើសុំទាំងនេះ ក្នុងគោលបំណងដើម្បីធានាដល់តម្លាភាព និងភាពពេញលេញនៃសំណុំរឿង។

## II. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ចៅក្រម Olivier Beauvallet និងចៅក្រម Kang Jin Baik បានបញ្ជូនតាមរយៈសារឡិចត្រូនិកនូវអនុស្សរណៈអន្តរការិយាល័យមួយ ("អនុស្សរណៈ ចុះថ្ងៃទី១២ ខែមីនា") មកកាន់សហព្រះរាជអាជ្ញា សហមេធាវី អោ អាន និង គ្រប់មេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់នៃសំណុំរឿង០០៤/២ ដោយបានចម្លងជូនចៅក្រម អ.ប.ជ ផ្សេងៗទៀត ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង និងប្រធានស្ដីទី និងអនុប្រធានការិយាល័យរដ្ឋបាល[1]។ អនុស្សរណៈថ្ងៃទី១២ ខែមីនា នេះ ក៏បានយោងឯកសារភ្ជាប់ចំនួនប្រាំបី ដែលត្រូវបានដាក់បញ្ចូលនៅក្នុងសារឡិចត្រូនិកនោះផងដែរ។

3. នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ លោកចៅក្រម ប្រាក់ គឹមសាន ដែលជាប្រធាន អ.ប.ជ បានចេញអនុស្សរណៈមួយ ("អនុស្សរណៈ ចុះថ្ងៃទី១៦ ខែមីនា") ទៅកាន់ការិយាល័យសហព្រះរាជអាជ្ញា

[1] អនុស្សរណៈអន្តរការិយាល័យពីលោក Beauvallet និងលោក Baik ចៅក្រម អ.ប.ជ ស្ដីពី "ការបញ្ជូនសំណុំរឿង០០៤/២" ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ("អនុស្សរណៈថ្ងៃទី១២ ខែមីនា")។

សហមេធាវី អោ អាន និង សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី[2] ដោយបានចម្លងជូនទៅក្រុមផ្សេងៗទៀតនៃ អ.ប.ជ និង ការិយាល័យរដ្ឋបាលផងដែរ[3]។

## III. ច្បាប់ជាធរមាន

4. កិច្ចព្រមព្រៀង អ.វ.ត.ក ចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖

> ក្នុងផលប្រយោជន៍ធានាឱ្យមានសវនាការជាសាធារណៈ ហើយដំណើរការត្រឹមត្រូវ និងទុកចិត្តបាន ត្រូវយល់ថា តំណាងរបស់រដ្ឋសមាជិកនៃអង្គការសហប្រជាជាតិ តំណាងរបស់លោកអគ្គលេខាធិការ តំណាងបណ្ដាញពត៌មាន និងតំណាងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ នឹងអាចចូលរួមស្ដាប់ការជំនុំជម្រះក្ដីបានគ្រប់ពេលវេលាទាំងអស់[4]។

5. វិធានផ្ទៃក្នុង ចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖

> ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្ដីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទជនជាប់ចោទ និង ជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ៖

---

[2] ស.ព.អ កត់សម្គាល់ថា អនុស្សរណៈទាំងពីរត្រូវបានផ្ញើទៅកាន់មេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ យ៉ាងណាក៏ដោយបច្ចុប្បន្ននេះ វាពុំមានសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានទទួលស្គាល់នៅក្នុងសំណុំរឿង០០៤/២ នេះទេហើយ ដោយវាពុំមានអាសយដ្ឋានអ៊ីមែលដែលដំណើរការបានរបស់បុគ្គលខ្លះក្នុងចំណោមមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី នោះវាមិនច្បាស់លាស់ទេថា ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានជូនដំណឹងគ្រប់ជ្រុងជ្រោយអំពីការវិវត្តន៍ទាំងនេះ និងស្ថានភាពបច្ចុប្បន្ននៃសំណុំរឿងនេះ។

[3] អនុស្សរណៈពីលោក ប្រាក់ គឹមសាន ក្រោមចំណងជើងថា "ការបញ្ជាក់ឡើងវិញពីសេចក្ដីសម្រេចលើសំណុំរឿង០០៤/២" ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ("អនុស្សរណៈថ្ងៃទី១៦ ខែមីនា")។

[4] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ("កិច្ចព្រមព្រៀង អ.វ.ត.ក") មាត្រា ១២(២)។

ក- ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ។ [...]

គ- អង្គជំនុំជម្រះវិសាមញ្ញ ត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី [...][5]។

## IV. សេចក្តីសន្និដ្ឋាន

6. ដូចដែល អ.ប.ជ បានដឹងហើយថា ភាគីទាំងឡាយបានកំពុងស្វែងរកការបំភ្លឺទាក់ទងនឹងជំហានបន្ទាប់ទៀតនៅក្នុងសំណុំរឿង០០៤/២ ចាប់តាំងពីពេលដែលសេចក្តីពិចារណារបស់ អ.ប.ជ ត្រូវបានចេញនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩[6]។ មិនមានការបំភ្លឺណាមួយទេ រហូតទាល់តែអនុស្សរណៈចុះថ្ងៃទី១២ ខែមីនា និងថ្ងៃទី១៦ ខែមីនា ត្រូវបានចេញ ទើប ស.ព.អ បានដឹងច្បាស់អំពីព័ត៌មានលម្អិតនៃការជាប់គាំងផ្នែកនីតិវិធី ដែលបានកើតមានឡើងនៅពីក្រោយឆាកនៅ អ.វ.ត.ក នេះ។

[5] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មទី៩) ដូចដែលបានកែប្រែនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធានផ្ទៃក្នុង") វិធាន ២១(១)។

[6] ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩។ *សូមមើល ឧទាហរណ៍* ឯកសារ **D359/25 & D360/34** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឱ្យចាត់វាល់វិធានការរដ្ឋបាលដែលតម្រូវទាំងអស់ ដើម្បីបញ្ជូនសំណុំរឿង ០០៤/០២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០។ ឯកសារ **D359/26 & D360/35** ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឱ្យចាត់វាល់វិធានការរដ្ឋបាលដែលតម្រូវទាំងអស់ ដើម្បីបញ្ជូនសំណុំរឿង ០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០។ ឯកសារ **D359/27 & D360/36** សំណើ [របស់ អោ អាន] សុំការបញ្ជាក់ថាបានចាត់វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ដើម្បីរក្សាសំណុំរឿង ០០៤/០២ ទុកក្នុងបណ្ណសារ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០។ ឯកសារ **D359/28 & D360/37** ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងចម្លើយតបរបស់ អោ អាន ទៅនឹងសំណើរបស់ ស.ព.អ ស្នើសុំឱ្យចាត់វាល់វិធានការរដ្ឋបាលទាំងអស់ដែលចាំបាច់ដើម្បីបញ្ជូនសំណុំរឿង០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០។ ឯកសារ **D359/30 & D360/39** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ អោ អាន ស្នើសុំការបញ្ជាក់ថាវិធានការរដ្ឋបាលដែលត្រូវការទាំងអស់ត្រូវបានធ្វើឡើងដើម្បីរក្សាសំណុំរឿង ០០៤/២ ទុកក្នុងបណ្ណសារ ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០២០។ ឯកសារ **D359/31 & D360/40** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ អោ អាន ស្នើសុំការបញ្ជាក់ថាវិធានការរដ្ឋបាលដែលត្រូវការទាំងអស់ត្រូវបានធ្វើឡើងដើម្បីរក្សាសំណុំរឿង ០០៤/២ ទុកក្នុងបណ្ណសារ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០។

ខណៈដែល ស.ព.អ ទទួលស្គាល់នូវគោលជំហររបស់ អ.ប.ជ ដែលថា មិនមានវិធានការរដ្ឋបាលបន្ថែមទៀតនឹងត្រូវធ្វើដោយ អ.ប.ជ នោះ[7] គាត់ស្នើសុំថា អនុស្សរណៈទាំងពីរ និងឯកសារភ្ជាប់ទៅនឹងអនុស្សរណៈចុះថ្ងៃទី១២ ខែមីនា ត្រូវបានដាក់បន្ថែមទៅក្នុងសំណុំរឿង និងធ្វើឲ្យទៅជាសាធារណៈ ដោយហេតុថា ឯកសារទាំងនោះមានប្រវត្តិនីតិវិធីសំខាន់ៗ ក៏ដូចជាទស្សនៈពេញលេញរបស់ អ.ប.ជ លើបញ្ហានេះ។ ឯកសារទាំងពីរប្រភេទនេះមានសារសំខាន់ ដើម្បីរក្សាទុកជាកំណត់ហេតុពេញលេញ និងមានតម្លាភាពនៃរឿងក្តីនេះ ដែលស្របគ្នាទៅនឹងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង អ.វ.ត.ក និងវិធានផ្ទៃក្នុង ដូចបានកត់សម្គាល់ខាងលើ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
| --- | --- | --- | --- |
| ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ | **លោកស្រី** **Brenda J. HOLLIS**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |

[7] អនុស្សរណាចុះថ្ងៃទី១២ ខែមីនា កថាខណ្ឌ៣៦។ អនុស្សរណៈចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ កថាខណ្ឌ ៥។